# ពាក្យសំដីរបស់ពួកគេ៖ ការពង្រឹងភាពអង់អាចដល់ប្រជាជនកម្ពុជាដែលមានពិការភាព តាមរយៈកិច្ចគាំពារសង្គម

នៅពេលដែលយើងរៀបចំប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាបន្នពិការភាព វាជាការចាំបាច់បំផុតក្នុងការធានាថាមតិយោបល់របស់ជនមានពិការភាពត្រូវបានរាប់បញ្ចូល។ បើទោះជាប្រទេសនីមួយៗមានកាតព្វកិច្ចក្នុងការធានាឱ្យមានការចូលរួមយ៉ាងសកម្មរបស់ជនមានពិការភាពក្តី ក៏ប៉ុន្តែជាញឹកញាប់ ការចូលរួមនេះហាក់ត្រឹមតែជាការចូលរួមជាតំណាងប៉ុណ្ណោះ ជាជាងការចូលរួមបែបសកម្ម[1]។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីលើកស្ទួយសំឡេងជនមានពិការភាព កម្មវិធី ACCESS បានសម្ភាសន៍អង្គការតំណាងជនមានពិការភាពនៅកម្ពុជា (OPDs) ចំនួន១២ ចាប់ពីខែមេសា ដល់ខែឧសភា ឆ្នាំ២០២១។[2] គោលដៅនៃការសម្ភាសន៍ទាំងនេះ គឺដើម្បីពិភាក្សាស្វែងយល់អំពីបញ្ហាប្រឈមនានាដែលជនមានពិការភាពជួបប្រទះក្នុងវដ្តជីវិតរបស់ពួកគេ ក៏ដូចជាដើម្បីស្តាប់នូវសំណូមពររបស់ពួកគេក្នុងបរិបទថា តើពួកគេអាចធ្វើឬចូលរួមយ៉ាងដូចម្តេចដើម្បីធ្វើឱ្យប្រព័ន្ធគាំពារសង្គមរបស់កម្ពុជាកាន់តែមានបរិយាបន្នពិការភាពបន្ថែមទៀត។ ទន្ទឹមនឹងពេលដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងចាត់វិធានការសំខាន់ៗដើម្បីពង្រឹងប្រព័ន្ធគាំពារសង្គមរបស់ខ្លួន សេចក្តីសង្ខេបគោលនយោបាយនេះ នឹងចូលរួមបង្ហាញអំពីគំនិតនានាដែលបានលើកឡើងដោយអង្គការតំណាងជនមានពិការភាព។

## ១ សនិទានភាពសម្រាប់ការផ្តល់តាវកាលិកពិការភាព

ជនមានពិការភាពទាំងអស់សុទ្ធតែជួបប្រទះនឹងការចំណាយបន្ថែមលើសពីជនដែលមិនមានពិការភាព។ នៅទូទាំងពិភពលោក ការសិក្សានានាប៉ាន់ស្មានថា គ្រួសារដែលមានសមាជិកមានពិការភាពត្រូវការចំណាយចន្លោះពី ៨ ទៅ ៥៨ភាគរយ នៃប្រាក់ចំណូលបន្ថែមទៀតដើម្បីឈានដល់កម្រិតជីវភាព និងការរស់នៅសមរម្យស្របតាមស្តង់ដារជីវិតដូចគ្រួសារដែលមិនមានសមាជិកមានពិការភាព[3]។ នៅកម្ពុជា ការចំណាយបន្ថែមនេះត្រូវបានគេប៉ាន់ស្មានថាមានប្រមាណ ១៨,៦ភាគរយ[4]។ ការចំណាយបន្ថែមអាចជាការចំណាយដោយផ្ទាល់៖ ឧទាហរណ៍ កុមារដែលពិបាកក្នុងការ

[1] សូមមើល Devandas-Aguilar (2015)

[2] តំណាងអង្គការតំណាងជនមានពិការភាព (OPD) ត្រូវបានសម្ភាសន៍ជាគូ ដោយក្នុងនោះ មានអ្នកផ្តល់ព័ត៌មានរបស់ OPD ជាប្រុសម្នាក់ និងស្រីម្នាក់មកពីខេត្តដូចគ្នា។ អ្នកផ្តល់ព័ត៌មានទាំងពីរនេះមកពី OPDs ផ្សេងគ្នា ដែលតំណាងឱ្យជនដែលមានពិការភាពប្រភេទផ្សេងៗនៅក្នុងខេត្តតែមួយ ហើយអ្នកផ្តល់ព័ត៌មានជាស្ត្រីជារបស់អង្គការស្ត្រី។ លើសពីនេះទៀត អង្គការតំណាងជនពិការកម្ពុជាថ្នាក់ជាតិ ត្រូវបានសម្ភាសន៍ផងដែរ។ គេគួរកត់សម្គាល់ថា ការគ្របដណ្តប់នៅមានកម្រិតនៅឡើយ។ ឧទាហរណ៍ បុគ្គលដែលមានពិការភាពខាងសតិបញ្ញា និងមនុស្សចាស់ មិនសូវជាមានតំណាងនោះទេ។

[3] See Kidd et al (2019)

[4] Palmer et al (2019)

កញ្ញា ២០២២

រៀបចំដោយ DEVELOPMENT PATHWAYS




ចល័តទីអាចត្រូវការការចំណាយសម្រាប់មធ្យោបាយដឹកជញ្ជូនដាក់លាក់ដើម្បីទៅសាលារៀន។

ទោះជាយ៉ាងណាក៏ដោយ ការចំណាយទាំងនេះក៏អាចជាការចំណាយដោយប្រយោលផងដែរ ប្រសិនបើគ្រួសាររកប្រាក់បានតិច។ ឧទាហរណ៍ ជនមានពិការភាពប្រហែលជាមិនអាចទទួលបានការងារនោះទេ ព្រោះទីកន្លែងធ្វើការមិនមានផាសុកវត្ថុ។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ៨១ភាគរយ នៃមនុស្សពេញវ័យមានពិការភាពគ្រប់អាយុធ្វើការមិនបានធ្វើការនោះទេ បើធៀបនឹង ១០% នៃជនដែលមិនមានពិការភាព។ ហើយទោះបីជាជនមានពិការ-ភាពមានការងារធ្វើក៏ដោយ ក៏ពួកគេទំនងជាធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយរកប្រាក់ចំណូលបានតិចជាងជនដែលមិនមានពិការភាព។ ក្នុងករណីមានបញ្ហាហិរញ្ញវត្ថុ ពួកគេអាចនឹងត្រូវបានបង្ខំចិត្តឱ្យជ្រើសរើសយកយុទ្ធសាស្ត្រដោះស្រាយបែបអវិជ្ជមាន ដូចជាការលក់ទ្រព្យ ឬការខ្ចីប្រាក់គេ។ លើសពីនេះទៀត ប្រសិនបើពួកគេមានតម្រូវការថែទាំខ្ពស់ អ្នកថែទាំរបស់ពួកគេក៏ប្រហែលជាមិនអាចទៅធ្វើការបានដែរ។ ឪពុកម្តាយរបស់កុមារដែលមានអូទីស្សឹមបានរាយការណ៍ប្រាប់កម្មវិធី ACCESS ថា *"គ្រួសាររបស់គេមិនមានពេលមើលថែទាំកូន និងការងាររបស់ពួកគេ ហើយបញ្ហានេះបណ្តាលឱ្យមានការខ្វះខាតប្រាក់ចំណូល។"*

## ជាលទ្ធផល ជនមានពិការភាពជួបប្រទះបញ្ហាប្រឈមជាច្រើនដូចខាងក្រោម៖

- គ្រួសារដែលមានសមាជិកជាជនមានពិការភាព មានប្រាក់ចំណូលទាបជាងគ្រួសារដែលមិនមានសមាជិកជាជនមានពិការភាព ។
- គ្រួសារដែលមានសមាជិកមានពិការភាព មានកម្រិតជីវភាពទាបជាង ពីព្រោះពួកគេត្រូវបង់លើការចំណាយបន្ថែមសម្រាប់ពិការភាព ។
- នៅពេលគ្រួសារមិនអាចមានលទ្ធភាពបង់ការចំណាយបន្ថែមសម្រាប់ពិការភាព ជនមានពិការភាពទំនងជាត្រូវបានគេទុកចោល និងមិនអាចអនុវត្តសិទ្ធិពេញលេញរបស់ពួកគេសម្រាប់ការចូលរួមក្នុងសង្គមនោះទេ ។

> *"អ្នកមានពិការភាពធ្ងន់ធ្ងរ និងជាស្ត្រី ពួកគាត់ងាយរងគ្រោះកាន់តែខ្លាំង ។"*

ទោះបីជាជនមានពិការភាពទទួលរងការរើសអើងដោយសារហេតុផលមួយចំនួនក្តី បញ្ហានេះរឹតតែកើនឡើងនៅពេលពួកគេមិនមានប្រាក់ចំណូលឯករាជ្យ ឬនៅពេលដែលឪពុកម្តាយរបស់ពួកគេមិនទទួលបានតាវកាលិកសម្រាប់កុមារមានពិការភាព។ ក្នុងអំឡុងពេលសម្ភាសន៍ អង្គការតំណាងជនមានពិការភាពជាច្រើនបានប្រើពាក្យ "**បន្ទុក**" ដើម្បីពិពណ៌នាអំពីបញ្ហាប្រឈមដែលពួកគេជួបប្រទះ។ អង្គការតំណាងមួយបានពន្យល់ថា៖ *"សមាជិកគ្រួសារបន្ទោសជនមានពិការភាពហើយគិតថា ដោយសារតែជនមានពិការភាពទាំងនេះ ពួកគេមិនអាចធ្វើការ និងមិនអាចសងបំណុលធនាគារបាន។ ដូច្នេះជនមានពិការភាពមានការបាក់ទឹកចិត្តនិងទទួលរងការរើសអើងពីសមាជិកគ្រួសារ និងសហគមន៍របស់ពួកគេ។"*

[5] ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ ២០១៩

[6] សូមមើល ACCESS Cambodia (2022) ការវិភាគស្ថានភាពសម្រាប់ជនមានអូទីស្សឹមនៅក្នុងប្រទេសកម្ពុជា

ទោះជាយ៉ាងណាក៏ដោយ អង្គការតំណាងជនមានពិការភាពកត់សម្គាល់ឃើញកាន់តែច្បាស់ថានៅពេលដែលជនមានពិការភាពមានប្រាក់ចំណូលខ្លួនឯង ពួកគេហាក់ទទួលរងការរើសអើងតិចជាងមុន។ អង្គការតំណាងមួយបាននិយាយថា៖ *"សម្រាប់ជនដែលមានពិការភាពដែលមានការងារ និងមុខរបរត្រឹមត្រូវ គឺមិនត្រូវបានគេរើសអើងនោះទេ"* ហើយម្នាក់ទៀតឮល់ថា៖ *"ប្រសិនបើ ស្ត្រី គ្មានការងារធ្វើ ឬមុខរបរទេនោះ ពួកគេត្រូវបានសមាជិកគ្រួសាររើសអើង ហើយពួកគេមិនត្រូវបានសមាជិកសហគមន៍ចូលចិត្តរាប់អាននោះទេ។ ប្រសិនបើពួកគេគ្មានការងារធ្វើ ឬគ្មានមុខរបរ ពួកគេគ្មានតម្លៃនោះទេ"*។ ប្រាក់ចំណូលផ្ទាល់ខ្លួនឬឯករាជ្យចូលរួមចំណែកជួយជនមានពិការភាពក្នុងការកាត់បន្ថយនូវអ្វីដែលអង្គការតំណាងជនមានពិការភាព យល់ថាជា "**បន្ទុក**" ដោយហេតុថាវាអាចឱ្យពួកគេចូលរួមក្នុងគ្រួសារ និងសហគមន៍របស់ពួកគេបានកាន់តែប្រសើរ។ ប្រសិនបើពួកគេកាន់តែឯករាជ្យ និងពឹងផ្អែកលើអ្នកដទៃកាន់តែតិច ហើយអាចរួមចំណែកជាថវិកាផងនោះ ជនមានពិការភាពអាចពង្រឹងទំនាក់ទំនងរបស់ពួកគាត់ក្នុងសង្គម និងបង្កើតជាសុច្ឆន្ទៈបានកាន់តែច្រើន។

ដូច្នេះ កិច្ចគាំពារសង្គម ជាពិសេសតាមរយៈការផ្ដល់តាវកាលិកពិការភាព គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតមួយក្នុងការផ្ដល់ភាពអង់អាចដល់ជនមានពិការភាព។ ប្រសិនបើកញ្ចប់តាវកាលិកពិការភាពមានកម្រិតខ្ពស់គ្រប់គ្រាន់ វាអាចផ្ដល់ដល់ជនមានពិការភាពដែលមិនអាចធ្វើការបាននូវប្រាក់ចំណូលឯករាជ្យ។ តាវកាលិកនេះក៏អាចគ្របដណ្ដប់លើការចំណាយបន្ថែមនៃពិការភាព ដែលជនមានពិការភាពទាំងអស់ត្រូវរ៉ាប់រង។ ប្រាក់ចំណូលគ្រប់គ្រាន់អនុញ្ញាតឱ្យជនមានពិការភាពមានលទ្ធភាពក្នុងការចំណាយសម្រាប់ទំនិញនិងសេវាកម្មនានា ក៏ដូចជាថ្លៃសេវាសុខភាព និងការអប់រំកាន់តែប្រសើរឡើង និងអាចស្វែងរកការងារធ្វើបាន[7]។ **ដូច្នេះ ការវិនិយោគលើជនមានពិការភាពគឺជាមធ្យោបាយមួយនៃការវិនិយោគទៅលើប្រទេសមួយដែរ។** តាមការពិតគេប៉ាន់ប្រមាណថា ប្រសិនបើគេមិនដោះស្រាយបញ្ហាពិការភាពប្រកបដោយប្រសិទ្ធភាពទេនោះ ប្រទេសដែលមានចំណូលទាប និងមធ្យមអាចទទួលរងការបាត់បង់ផលិតភាពការងារចាប់ពី ១ ទៅ ៧ភាគរយ នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)។[8]



[7] See Burchardt (2000); Devandas-Aguilar (2015); Kidd et al (2019)
[8] See Buckup (2009) in Banks and Polack (2014)

# ២ ការរៀបចំបង្កើតតាវកាលិកពិការភាព

*ប្រាក់ឧបត្ថម្ភពិការភាពគឺជាតាវកាលិកបុគ្គលមួយដែលផ្តល់ដល់ជនមានពិការភាព។ ទោះបីជាយ៉ាងណាក្តី អង្គការតំណាងជនមានពិការភាពតិចណាស់ដែលដឹងអំពីអត្ថប្រយោជន៍នេះ ក៏ដោយសារតែការផ្សព្វផ្សាយនិងការគ្របដណ្តប់នៃកម្មវិធីនេះនៅមានកម្រិតនៅឡើយ។ អង្គការតំណាងបានដឹងច្បាស់អំពីកម្មវិធីផ្ទេរាច់ប្រាក់សម្រាប់អ្នកមានប័ណ្ណសមធម៌ក្នុងអំឡុងពេលជំងឺកូវីដ-១៩។ តាវកាលិកនៃកម្មវិធីនេះផ្តោតលើគ្រួសារក្រីក្រ ហើយបានផ្តល់នូវការគាំទ្រកាន់តែច្រើនថែមទៀតដល់គ្រួសារដែលមានសមាជិកជាជនមានពិការភាព។*

ភាគច្រើននៃអង្គការតំណាងជនមានពិការភាព មានទស្សនៈវិជ្ជមានចំពោះការពិតដែលថា រាជរដ្ឋាភិបាលកម្ពុជាកំពុងផ្តល់ប្រាក់ឧបត្ថម្ភពិការភាពដល់ពលរដ្ឋរបស់ខ្លួន ក៏ដូចជាការផ្ទេរសាច់ប្រាក់សម្រាប់ជនក្រីក្រដែលមានសមធម៌ក្នុងអំឡុងពេលជំងឺកូវីដ-១៩។ ទោះបីជារបបគោលនយោបាយទាំងនេះ ត្រូវបានផ្តល់និងទទួលគ្រប់គ្រាន់ក៏ដោយ ក៏អង្គការតំណាងជនមានពិការភាពបានកត់សម្គាល់ឃើញថា វាអាចមានហានិភ័យនិងកត្តាប្រឈមមួយចំនួនចំពោះការបង្កើតនិងរៀបចំតាវកាលិកទាំងនោះ ដែលនេះអាចជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំ និងបង្កើតតាវកាលិកថ្មីនាពេលអនាគត។ គេគួរកត់សម្គាល់ថា ទោះបីជាដំណើរការកម្មវិធីកំណត់អត្តសញ្ញាណពិការភាពបានរៀបចំក្នុងកម្រិតទូទាំងប្រទេសក៏ដោយ ក៏នៅពេលសម្ភាសន៍ អង្គការតំណាងបានបញ្ជាក់ថាកម្មវិធីនេះស្ថិតក្នុងដំណាក់កាលដំបូងៗនៅឡើយ ហើយការអនុវត្តជាក់ស្តែងនៅមិនទាន់គ្រប់គ្រាន់និងទូលំទូលាយនៅឡើយ។

## ២.១ ហានិភ័យ និងកត្តាប្រឈមនៃតាវកាលិកដែលផ្តោតលើភាពក្រីក្រសម្រាប់គ្រួសារក្រីក្រ

នៅពេលនិយាយអំពីដំណើរការកំណត់អត្តសញ្ញាណកម្មសម្រាប់ការផ្ទេរសាច់ប្រាក់ជំងឺកូវីដ-១៩ ដែលផ្តោតគោលដៅលើភាពក្រីក្រ អង្គការតំណាងជនមានពិការភាពជាច្រើនបានបញ្ជាក់ថា អ្នកទទួលផលគួរតែត្រូវបានវាយតម្លៃជាលក្ខណៈបុគ្គលជាជាងគ្រួសារ។ នេះគឺដោយសារតែជនមានពិការភាពដែលរស់នៅក្នុងគ្រួសារ "ដែលមានទ្រព្យធនច្រើន" មិនអាចបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានតាវកាលិកនេះទេ បើទោះបីជាពួកគេមិនមានប្រាក់ចំណូលខ្លួនឯងក្តី។ ទោះជាយ៉ាងណាក៏ដោយ ដោយផ្អែកលើមូលដ្ឋានបុគ្គល ពួកគេនឹងត្រូវបានវាយតម្លៃថាមិនមានប្រាក់ចំណូល ដូច្នេះពួកគេអាចបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានតាវកាលិកនេះ។ អង្គការតំណាងជនមានពិការភាពបានពន្យល់ដូចខាងក្រោម៖

*"ខ្ញុំតែងតែស្នើសុំឱ្យរដ្ឋាភិបាលយកចិត្តទុកដាក់លើស្ថានភាពជាក់ស្តែងរបស់ជនមានពិការភាព។ ពួកគេភាគច្រើនពឹងផ្អែកលើសមាជិកគ្រួសារ ប៉ុន្តែជួនកាលសមាជិកគ្រួសាររបស់ពួកគេមិនបានថែទាំពួកគេឱ្យបានល្អឡើយ ហើយពួកគេទទួលរងការរើសអើងផងដែរ។ ប្រសិនបើពួកគេគ្មានប្រាក់ចំណូលដោយខ្លួនឯងទេ ពួកគេមិនសូវទទួលបានការយកចិត្តទុកដាក់ឡើយ។ នេះជាមូលហេតុដែលការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ មិនគួរផ្តោតលើគ្រួសារនោះទេ ព្រោះជនមានពិការភាពពឹងផ្អែកលើសាច់ញាតិនិងបងប្អូនបង្កើតរបស់ពួកគេ ហើយប្រហែលជាមិនទទួលបានការគាំទ្រពេញលេញនោះទេ។ ចូរពិនិត្យមើលស្ថានភាពជាក់ស្តែងរបស់ជនមានពិការភាព ពីព្រោះពួកគេជាច្រើនកំពុងរងទុក្ខលំបាក។ ពួកគេរស់នៅជាមួយសមាជិកគ្រួសារដទៃទៀតដើម្បីជាទីជម្រកប៉ុណ្ណោះ"។*

*"ខ្ញុំដឹងពីករណីស្ត្រីមានពិការភាពម្នាក់ ហើយមិនអាចធ្វើការបាន ប៉ុន្តែអាជ្ញាធរមូលដ្ឋាននិយាយថា កូនរបស់គាត់ធ្វើការ ដូច្នេះគាត់អាចទទួលបានការគាំទ្រពីកូនរបស់គេហើយ។ នេះជាការលំបាកខ្លាំងណាស់។ កូនម្នាក់ផ្តល់ការឧបត្ថម្ភ ប៉ុន្តែកូនផ្សេងទៀតយកលុយនោះទៅសងបំណុលធនាគារ ធ្វើឱ្យនាងធ្លាក់ក្នុងស្ថានភាពលំបាកដដែល"។*

**ជាការពិតណាស់ជនមានពិការភាពទាំងអស់–មិនថាពួកគេកំពុងរស់នៅជាមួយប្រាក់ចំណូលទាប ឬខ្ពស់នោះទេ គឺមានសិទ្ធិទទួលបានការធានានូវប្រាក់ចំណូលអប្បបរមា។** នេះគឺដោយសារតែជនមានពិការភាពទាំងអស់ទទួលរង និងប្រឈមនឹងហានិភ័យនៃវដ្តជីវិតដោយសារតែការចំណាយបន្ថែមផ្សេងទៀត ដែលរួមចំណែកជាឧបសគ្គដែលពួកគេប្រឈម។ ដូចដែលអង្គការតំណាងជនមានពិការភាពមួយបានពន្យល់ថា៖ *"ក្នុងអំឡុងពេលរាតត្បាតជំងឺកូវីដ-១៩ រដ្ឋាភិបាលបានផ្ទេរប្រាក់ទៅឱ្យជនមានពិការភាព ប៉ុន្តែមិនបានផ្ទេរទៅឱ្យពួកគេគ្រប់គ្នានោះទេ។ លុះត្រាណាតែពួកគេមានប័ណ្ណសមធម៌ ទើបពួកគេអាចមានសិទ្ធិទទួលបានសាច់ប្រាក់។ សម្រាប់អ្នកដែលមិនមានប័ណ្ណសមធម៌នេះ ពួកគេក៏អាចទទួលបានប័ណ្ណនេះដែរ ប៉ុន្តែអាស្រ័យលើអាជ្ញាធរមូលដ្ឋាននិងមេឃុំ ហើយប្រសិនបើពួកគេយល់ពីការលំបាក និងការឈឺចាប់របស់ពួកគេ។ ដូច្នេះមិនមែនគ្រប់គ្នាដែលមានពិការភាពសុទ្ធតែទទួលបានការគាំទ្រនោះទេ ប៉ុន្តែជាទូទៅវាប្រសើរជាងគ្មានអ្វីសោះ"* ។



ទស្សនៈរបស់អង្គការតំណាងជនមានពិការភាពគឺស្របតាមចលនាពិការភាពសកល នៅជុំវិញពិភពលោក អ្នកស្វែងរកមតិគាំទ្រក៏កំពុងអំពាវនាវឱ្យផ្លាស់ប្តូរប្រព័ន្ធគាំពារសង្គមពីបែបវិធីសាស្ត្រសប្បុរសធម៌ទៅជាវិធីសាស្ត្រដែលផ្អែកលើសិទ្ធិជាចំបង[9]។ ប្រព័ន្ធគាំពារសង្គមមិនគួរផ្តោតលើថាតើមនុស្សអាចធ្វើការបានឬអត់នោះទេ ផ្ទុយទៅវិញត្រូវតែទទួលស្គាល់ថា ជនមានពិការភាពទាំងអស់មានសិទ្ធិទទួលបានតាវកាលិកពិការភាព ដូច្នេះពួកគេអាចទទួលបានឱកាសស្មើគ្នាដូចពលរដ្ឋដទៃទៀតក្នុងសង្គម។ ប្រសិនបើគ្មានតាវកាលិកទេ ជនមានពិការភាព (ដោយមិនគិតពីស្ថានភាពទ្រព្យធនក្នុងគ្រួសាររបស់ពួកគេ) អាចប្រឈមនឹងការពឹងផ្អែកលើសមាជិកគ្រួសាររបស់ពួកគេ ឬមិនអាចមានលទ្ធភាពរ៉ាប់រងការចំណាយបន្ថែមរបស់ពួកគេបានឡើយ។

## ២.២ ហានិភ័យ និងកត្តាប្រឈមនៃការផ្តល់តាវកាលិកដល់គ្រួសារជាជាងបុគ្គល

អង្គការតំណាងជនមានពិការភាពជាច្រើនបានបញ្ជាក់ថា ការផ្តល់តាវកាលិកដល់គ្រួសារជាជាងបុគ្គលនោះជារឿយៗ មានន័យថាជនមានពិការភាពមិនបានទទួលតាវកាលិកនោះទេ។ នៅក្នុងប្រទេសកម្ពុជាតាវកាលិកគ្រួសារជាទូទៅត្រូវបានគេប្រគល់ជូនមេគ្រួសារ។ ដូចដែលអង្គការតំណាងជនមានពិការភាពមួយបានពន្យល់ថា *"ប្រសិនបើពួកគេមិនមែនជាមេគ្រួសារទេពួកគេមិនអាចប្រើប្រាស់សាច់ប្រាក់នោះបានពេញលេញនោះទេ។ យ៉ាងហោចណាស់វាប្រសើរជាងគ្មានអ្វីសោះ"*។ ទោះបីវាជាការពិតដែលថា ការផ្ទេរសាច់ប្រាក់ជំងឺកូវីដ-១៩ បានវិភាជថវិកាសម្រាប់សមាជិកគ្រួសារដែលមានពិការភាពក៏ដោយ។

ការបែងចែកទ្រព្យសម្បត្តិនៅក្នុងគ្រួសារមួយ គឺអាស្រ័យទៅលើតុល្យភាពនៃអំណាចនៅក្នុងគ្រួសារនោះ។ ប្រសិនបើជនមានពិការភាពទទួលរងការផាត់ចេញពីសង្គម ពេលនោះពួកគេទំនងជាមិនអាចទទួលបានតាវកាលិកពីរបបគោលនយោបាយគ្រួសារឡើយ។ គេគួរកត់សម្គាល់ថា ទោះបីជាមិនមែនគ្រប់ជនមានពិការភាព

[9] ដូចមានចែងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ។ សូមមើលការពិភាក្សាផងដែរនៅក្នុង ពិការភាព-កិច្ចគាំពារសង្គម-បរិយាន្ន៖ ព្រឹត្តិការណ៍កិច្ចសន្ទនាសម្រាប់ការផ្លាស់ប្តូរ។



ទាំងអស់ទទួលរងការផាត់ចេញពីសង្គមក៏ដោយ មនុស្សចាស់ ឬអ្នកដែលមានពិការភាពធ្ងន់ធ្ងរជាងនេះ មានហានិភ័យកាន់តែច្រើនជាងគេ។ នៅពេលពិភាក្សាអំពីការផ្ទេរសាច់ប្រាក់ជំងឺកូវីដ-១៩ អង្គការតំណាងជនមានពិការភាព បានលើកឡើងថា៖ *“ជួនកាល សមាជិកគ្រួសារមិនបានប្រាប់ដល់ជនមានពិការភាព ថាពួកគេបានទទួលតាវកាលិកទេ ពីព្រោះប័ណ្ណសមធម៌គឺសម្រាប់គ្រួសារ មិនមែនសម្រាប់បុគ្គលទេ។ ដូច្នេះពួកគេមិនប្រាប់ជនមានពិការភាពថា សាច់ប្រាក់នេះមួយផ្នែកគឺសម្រាប់ជួយពួកគេនោះទេ។ ជួនកាលពួកគេគិតថាវាមិនចាំបាច់ពីព្រោះពួកគេគឺជាអ្នកក្នុងបន្ទុក"*។ ហើយគេបានពន្យល់ថា៖ *“មេគ្រួសារមិនបានប្រាប់ដល់ជនមានពិការភាពអំពីតាវកាលិកគ្រួសារនោះទេ ដោយសារពួកគេមិនគិតថាវាសំខាន់ ពីព្រោះតាវកាលិកនេះគឺសម្រាប់គ្រួសារទាំងមូល...។ នៅពេលខ្ញុំសួរជនមានពិការភាព ពួកគេនិយាយថា ពួកគេមិនដឹងថាពួកគេទទួលបានប្រាក់ឧបត្ថម្ភប៉ុន្មានទេ ព្រោះមេគ្រួសារ ឬឪពុកម្ដាយមិនបានប្រាប់ពួកគេនោះទេ"*។

ប្រសិនបើតាវកាលិកត្រូវបានផ្តល់ដល់គ្រួសារនោះ ស្ត្រី និងកុមារមានពិការភាព ទំនងជាមិនទទួលបានតាវកាលិកទេ។ នៅក្នុងប្រទេសកម្ពុជា មេគ្រួសារច្រើនតែជាបុរស។ ដូច្នេះស្ត្រីក្នុងគ្រួសារ រួមទាំងស្ត្រីមានពិការភាពផងដែរ ពឹងផ្អែកលើមេគ្រួសារដើម្បីចែករំលែកតាវកាលិកនោះ ដើម្បីឱ្យពួកគេអាចបំពេញតម្រូវការរបស់ពួកគេបាន។

ដូច្នេះ ប្រព័ន្ធគាំពារសង្គមដែលមានបរិយាបន្នពិការភាព គួរតែផ្តល់ដល់ជនមានពិការភាពនូវតាវកាលិកជាលក្ខណៈបុគ្គលជាជាងតាវកាលិកជាគ្រួសារ។ នេះគឺស្របទៅនឹងអ្វីដែលគេសង្កេតឃើញនៅជុំវិញពិភពលោកដែលក្នុងនោះ តាវកាលិកពិការភាពគឺជាសិទ្ធិបុគ្គល[10]។ តាមការពិត តាវកាលិកដែលត្រូវបានផ្តល់ដល់គ្រួសារ (ប៉ុន្តែផ្តល់ការផ្ទេរសាច់ប្រាក់កាន់តែច្រើនសម្រាប់ជនមានពិការភាព) មិនត្រូវបានគេហៅថា តាវកាលិកពិការភាពទេ។ ផ្ទុយទៅវិញវាគឺជាតាវកាលិកទូទៅដែលគេផ្តល់សម្រាប់ជនមានពិការភាព។

[10] សូមមើល មូលដ្ឋានទិន្នន័យតាវកាលិកពិការភាព សម្រាប់ទិដ្ឋភាពរួមនៃតាវកាលិកពិការភាពហិរញ្ញប្បទានដោយពន្ធនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម ។

**អាសយដ្ឋាន:** អគារលេខ ២៤០ ជាន់ទី៣ អគារ អានីណា ផ្លូវ ២៧១
សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**ទូរស័ព្ទ:** (៨៥៥) ១២ ៨៧៦ ៥៤៩
**អ៊ីម៉ែល:** info@accesscambodia.org
**វេបសាយ:** www.accesscambodia.org

## ២.៣ ភាពគ្រប់គ្រាន់នៃសាច់ប្រាក់ផ្ទេរ

ទោះបីជាអង្គការតំណាងជនមានពិការភាព បានបញ្ជាក់ថា ពួកគេសប្បាយចិត្តដែលជនមានពិការភាពត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធគាំពារសង្គមរបស់ប្រទេសកម្ពុជាក៏ដោយ ក៏ពួកគេយល់ថា តាវកាលិកដែលផ្ទេរជូនបច្ចុប្បន្ននឹងមិនទាន់មានចំនួនសមស្រប ដើម្បីដោះស្រាយហានិភ័យដែលជនមានពិការភាពប្រឈមនោះទេ។ ឧទាហរណ៍ នៅពេលនិយាយអំពីប្រាក់ឧបត្ថម្ភពិការភាពប្រចាំខែក្នុងចំនួនទឹកប្រាក់ ២០,០០០ រៀល អង្គការតំណាងជនមានពិការភាពមួយបានពន្យល់ថា *"វាតិចតួចពេកដែលមិនអាចរស់បាន ប៉ុន្តែវាប្រសើរជាងអត់សោះ។ ទោះបីជាយ៉ាងណាក៏ដោយយើងស្នើសុំច្រើនជាងនេះ ហើយរដ្ឋាភិបាលគួរតែពិចារណាឡើងវិញ"*។ អង្គការតំណាងជនមានពិការភាពមួយទៀតបានបញ្ជាក់ថា ការផ្ទេរសាច់ប្រាក់ជំងឺកូវីដ-១៩ *"អាចសម្រាលបន្ទុកបាន។ ប៉ុន្តែជនមានពិការភាពធ្ងន់ធ្ងរខ្លះក៏ត្រូវការក្រណាត់កន្ទប និងឧបករណ៍ជំនួយដាក់លាក់ផងដែរ ដូច្នេះ ជួនកាលការផ្ទេរសាច់ប្រាក់នេះគឺមិនគ្រប់គ្រាន់ទេ...។ ក្នុងអំឡុងពេលនៃការបិទខ្ទប់ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាត្រូវបានបិទទ្វារ ប្រជាជនមិនអាចទៅមន្ទីរពេទ្យបានទៀតទេ ដូច្នេះការចំណាយរបស់ពួកគេកើនឡើងទ្វេដង ។"*

### ប្រសិនបើជនមានពិការភាពត្រូវបានទទួលតាវកាលិកគាំពារសង្គម ចំនួនសាច់ប្រាក់នៃការផ្ទេរគួរត្រូវតែះ

ក) ផ្តល់ជាប្រាក់ចំណូលជំនួស សម្រាប់អ្នកដែលត្រូវការជំនួយបែបនេះ

ខ) គ្របដណ្តប់លើការចំណាយបន្ថែមនៃពិការភាព ដែលអាចរួមបញ្ចូលតម្រូវការជាច្រើន ដូចជាសម្ភារបរិក្ខារពេទ្យ ការថែទាំសុខភាព និងឱសថ ការដឹកជញ្ជូន និងប្រាក់ខែសម្រាប់អ្នកជំនួយការផ្ទាល់ខ្លួនរបស់ពួកគេម្នាក់។

នៅក្នុងប្រទេសកម្ពុជា គេបានប៉ាន់ប្រមាណថា ជាមធ្យមគ្រួសារដែលមានសមាជិកមានពិការភាពម្នាក់ត្រូវការប្រាក់ ១២,០០០ រៀល ក្នុងមួយថ្ងៃ ដើម្បីរក្សាបាននូវកម្រិតជីវភាពដូចគ្រួសារដែលមានប្រាក់ចំណូលដូចគ្នា។[11] តាវកាលិកដែលមានសាច់ប្រាក់ផ្ទេរមិនគ្រប់គ្រាន់ ក៏នៅតែមានផលជះវិជ្ជមានទៅលើកម្រិតជីវភាពរស់នៅរបស់ពួកគេដែរ។ ទោះជាយ៉ាងណាក៏ដោយ តាវកាលិកនេះនឹងមិនធ្វើឱ្យមានការផ្លាស់ប្តូរជាក់លាក់ក្នុងរយៈពេលវែងឡើយ។

## ២.៤ យន្តការផ្តល់តាវកាលិក

> *"ប្រសិនបើបុគ្គលដែលមានពិការភាពធ្ងន់ធ្ងរ ហើយមិនអាចចេញក្រៅបាន ឬក្នុងករណីខ្លះ ពួកគេនៅតែឯងការធ្វើដំណើរអាចជាឧបសគ្គ។ ដូច្នេះហើយបានជា ពួកគេអាចស្នើឱ្យក្មួយប្រុសណាម្នាក់របស់ពួកគេទៅបើកប្រាក់ឱ្យពួកគេ។ ប្រសិនបើសាច់ញាតិពួកគេស្មោះត្រង់ ពួកគេទទួលបានប្រាក់នោះ។ ប៉ុន្តែសម្រាប់អ្នកដែលសាច់ញាតិពួកគេមិនស្មោះត្រង់ ពួកគេត្រូវខាតបង់ ។"*

យន្តការផ្ទេរសាច់ប្រាក់សម្រាប់តាវកាលិកគាំពារសង្គម ត្រូវតែពិចារណាពីការពិតដែលថា ជនមានពិការភាពអាចមិនត្រូវបានគេផ្តល់សិទ្ធិអំណាចនៅក្នុងគ្រួសាររបស់ពួកគេនោះឡើយ។ ប្រសិនណាបើជនមានពិការភាព មិនដកយកតាវកាលិកនោះដោយខ្លួនឯងទេនោះ គេមិនអាចធានាថា ពួកគេនឹងទទួលបានថវិកានោះទេ។ បញ្ហានេះត្រូវបានបញ្ជាក់នៅក្នុងការសិក្សានៅខាងក្រៅប្រទេសកម្ពុជា៖ ឧទាហរណ៍ ប្រហែលមួយភាគបីនៃមនុស្សពេញវ័យដែលទទួលបានតាវកាលិកពិការភាពនៅក្នុងប្រទេសវៀតណាម នេប៉ាល់ និងម៉ាល់ឌីវ បានរាយការណ៍ថាថវិការបស់ពួកគេត្រូវបានគ្រប់គ្រងដោយអ្នកផ្សេងទៀតក្នុងគ្រួសាររបស់ពួកគេ។[12] ដូច្នេះយើងគួរស្វែងរកដំណោះស្រាយដើម្បីធានាថា ជនមានពិការភាពអាចដកតាវកាលិករបស់ពួកគេដោយខ្លួនឯងបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។ ឧទាហរណ៍ បញ្ជរផ្ទេរប្រាក់ចល័តត្រូវមានភាពងាយស្រួលប្រើប្រាស់សម្រាប់ជនដែលមានការលំបាកក្នុងការបំលាស់ទី ឬក្នុងករណីដែលអ្នកទទួលផលត្រូវការអ្នកតំណាងដើម្បីគ្រប់គ្រងតាវកាលិករបស់ពួកគេ គេគួររៀបចំឱ្យមានប្រព័ន្ធត្រួតពិនិត្យសមស្របដើម្បីធានាថា មិនមានការរំលោភបំពានផ្នែកហិរញ្ញវត្ថុកើតឡើង។

[11] នេះគឺផ្អែកលើគ្រួសារពីរដែលរស់នៅដោយសារប្រាក់ចំណូលជាមធ្យមនៅក្នុងប្រទេសកម្ពុជាចំនួន ៧៥.៥០០ រៀល (US$19) ក្នុងមួយថ្ងៃ ។

[12] សូមមើលការពិភាក្សានៅក្នុង Banks et al (2021)

# សន្និដ្ឋាន

ជនមានពិការភាពយ៉ាងច្រើនមិនមានប្រភពចំណូលឯករាជ្យ ឬមិនអាចមានលទ្ធភាពរ៉ាប់រងលើការចំណាយបន្ថែមរបស់ពួកគេឡើយ។ ជាផលវិបាក ពួកគេត្រូវពឹងផ្អែកលើគ្រួសាររបស់ពួកគេ។ ពិតមែនតែជនមានពិការភាពខ្លះទទួលបានការថែទាំដោយក្ដីស្រលាញ់និងការគោរពក្ដី អ្នកខ្លះក៏បាត់បង់ស្វ័យភាព និងទទួលរងការផាត់ចេញពីសង្គម និងគ្មានសិទ្ធិអំណាចក្នុងការសម្រេចចិត្ត។ តាវកាលិកពិការភាពជាទៀងទាត់និងអាចព្យាករណ៍បានដែលត្រូវបានផ្ដល់ជូនជនមានពិការភាពដោយឈរលើមូលដ្ឋាននៃការផ្ដល់បែបបុគ្គល (ដោយមិនគិតពីកម្រិតប្រាក់ចំណូល) អាចពង្រឹងសិទ្ធិអំណាចរបស់ពួកគេ កាត់បន្ថយការរើសអើងនិងដាក់បញ្ចូលជនមានពិការភាពទៅក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ។

នៅពេលដែលប្រទេសកម្ពុជាពង្រឹងប្រព័ន្ធគាំពារសង្គមរបស់ខ្លួន គេចាំបាច់ត្រូវផ្ដល់ឱកាសដល់ជនមានពិការភាព ដើម្បីឱ្យពួកគេអាចចែករំលែកបទពិសោធន៍និងគំនិតរបស់ពួកគេ។ ការពិគ្រោះយោបល់បែបនេះ ត្រូវតែពិចារណាពីភាពចម្រុះនៃជនមានពិការភាព ដោយដាក់បញ្ចូលអ្នកដែលមានពិការភាពប្រភេទផ្សេងៗ រួមទាំងអាយុ ភេទ និងអ្នកដែលរស់នៅក្នុងតំបន់ទីក្រុងនិងជនបទ។ ដើម្បីសម្រេចបានគោលដៅនេះ គេអាចរៀបចំបង្កើតឱ្យមានប្រព័ន្ធគាំពារសង្គមប្រកបដោយ បរិយាបន្ននិងអាចប្រើប្រាស់បានសម្រាប់ជនមានពិការភាព។

